# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែមិថុនា ឆ្នាំ២០២៤

លេខ:០០៦


សេចក្តីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែមិថុនា របស់និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគាររួមមានដូចខាងក្រោម៖

## កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




១.កាលពីថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ និង **លោកស្រី ហា សុគន្ធា** ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈ ប្រព័ន្ធវីដេអូ Conference។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី “កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ” សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ

## ព័ត៌មានថ្មីៗ


កិច្ចប្រជុំគណៈកម្មាធិការ សូមអាននៅទំព័រ ................ ១

សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ ................ ២

កិច្ចប្រជុំគណៈកម្មាធិការ សូមអាននៅទំព័រ ................ ៣

កម្មវិធីប្រគល់វិញ្ញាបនបត្រ សូមអាននៅទំព័រ ................ ៣

សម្ភាសន៍ជ្រើសរើសមន្ត្រីលក្ខន្តិកៈ សូមអាននៅទំព័រ ................ ៤

សិក្ខាសាលា សូមអាននៅទំព័រ ................ ៥

កិច្ចប្រជុំក្រុមការងារមណ្ឌល សូមអាននៅទំព័រ ................ ៥

ទស្សនកិច្ចសិក្សា សូមអាននៅទំព័រ ................ ៦

សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ ................ ៦

សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ ................ ៧

កិច្ចប្រជុំលើកទី៤៩ សូមអាននៅទំព័រ ................ ៨

មហាសន្និបាត វ.គ.ស.ក. ប្រចាំឆ្នាំលើកទី២១ សូមអាននៅទំព័រ ................ ៨

វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ ................ ៩

សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ ................ ៩

ការបង្ហាញខ្លួនរបស់បេក្ខជន បេក្ខនារី ជាមន្ត្រីលក្ខន្តិកៈ សូមអាននៅទំព័រ ................ ១០

សិក្ខាសាលា សូមអាននៅទំព័រ ................ ១១

កិច្ចប្រជុំនេះបានពិភាក្សា សូមអាននៅទំព័រ ................ ១២

កិច្ចប្រជុំពិភាក្សាជាមួយ វ.គ.ស.ក.សូមអាននៅទំព័រ ................ ១២


© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម



២.កាលពីថ្ងៃចន្ទ ១២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹង ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី “កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ” សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុកប្តូមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ សរុបចំនួន២៩៥នាក់។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពី កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនដល់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងអ្នកដែលមានកាតព្វកិច្ចទទួលខុសត្រូវលើកិច្ចការងារគណនេយ្យរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ាន លើកទី២៤ (24th ACPACC)



៣.កាលពីថ្ងៃទី៤-៥ ខែមិថុនា ឆ្នាំ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ាន អមដោយមន្ត្រីជំនាញរួមមាន **លោក ណុប សម្បត្តិ** អនុប្រធាននាយកដ្ឋាន **លោក ស៊ុន ស៊ឹម** ប្រធានការិយាល័យ **លោក ជ រ័ត្ននា** អនុប្រធានការិយាល័យ និង **លោក ឃេង សុខធី** មន្ត្រីនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៤ (24th ACPACC) និងចូលរួមកិច្ចប្រជុំពាក់ព័ន្ធផ្សេងទៀត នៅខេត្តសៀមរាប ប្រទេសកម្ពុជា ក្នុងគោលបំណងចម្បងនៃកិច្ចប្រជុំលើកទី២៤ រួមមាន៖

**ទី១**.ការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រទេសជាសមាជិកអាស៊ានក្នុងនោះមានប្រទេសចំនួន៤គឺ ប្រុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងសឹង្ហបុរីប្រទេសថៃ បានកែសម្រួលនូវសេចក្តីថ្លែងការណ៍នៃការវាយតម្លៃរបស់ខ្លួន។

**ទី២**.ការធ្វើបច្ចុប្បន្នភាពលើចំនួនសមាជិកភាពនៃការចុះឈ្មោះជាគណនេយ្យករជំនាញអាស៊ាន (ASEAN CPAs) គិតត្រឹមខែឧសភា ឆ្នាំ២០២៤ មានចំនួនសរុប ៧,៤៦៨ រូប ក្នុងនោះប្រទេសកម្ពុជាមានចំនួន ១៩ រូប។

**ទី៣**.ការចុះឈ្មោះជាគណនេយ្យករជំនាញបរទេស (RFPAs) គិតត្រឹមខែឧសភា ឆ្នាំ២០២៤ មានចំនួនសរុប២៤ រូប។

**ទី៤**.ការចល័តរបស់គណនេយ្យករជំនាញអាស៊ាន (Mobility of ASEAN CPA) និងរាយការណ៍អំពីលទ្ធផលនៃការស្ទង់មតិលើចំណាប់អារម្មណ៍និងឧបសគ្គសម្រាប់ការចុះឈ្មោះជាគណនេយ្យករជំនាញអាស៊ាន និងគណនេយ្យករជំនាញបរទេស។

**ទី៥**.សកម្មភាពផ្សព្វផ្សាយ និងការកសាងសមត្ថភាពលើការជម្រុញលើការចុះឈ្មោះជាគណនេយ្យករជំនាញអាស៊ាន របស់គណនេយ្យករជំនាញរបស់ប្រទេសកម្ពុជា និងបណ្តាប្រទេសជាសមាជិកអាស៊ាន ។

**ទី៦**.វឌ្ឍនភាពការងារក្នុងផែនទីបង្ហាញផ្លូវ ២០២០-២០២៥ ក្រោមកិច្ចព្រមព្រៀងការទទួលស្គាល់អញ្ញមញ្ញអាស៊ានលើសេវាគណនេយ្យ និងការពិភាក្សាពីផែនការសកម្មភាព ក្រោយឆ្នាំ២០២៥។

**ទី៧**.ការអនុម័តលើលក្ខខណ្ឌយោងការងារនៃក្រុមការងារ ការរាយការណ៍ព័ត៌មានចីរភាព។

**ទី៨**.កិច្ចប្រជុំរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៤ ជូនក្រុមការងារសេវាកម្មធុរកិច្ចតាមវិស័យដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការសម្របសម្រួលសេវាកម្មអាស៊ាន។

## កម្មវិធីប្រគល់វិញ្ញាបនបត្រសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"




៤.កាលពីថ្ងៃសុក្រ ១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកម្មវិធីប្រគល់វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"នៅអគារ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋាន កិច្ចការគតិយុត្តនិងអនុលោមភាព

វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី **លោក សាយ សុខខេង** អគ្គនាយក ក្រុមហ៊ុន ឌីអេស្វស៊ី (DFC) ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម និងសិក្ខាកាមដែលបានប្រឡងជាប់ស្ពាពរចំនួន១១១នាក់។

## ប្រឡងប្រជែងលើវិញ្ញាសាសម្ភាសន៍ជ្រើសរើសមន្ត្រីលក្ខន្តិកៈ ចំនួន១៥រូប ឱ្យចូលបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម



៥.កាលពីថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំការប្រឡងប្រជែងលើវិញ្ញាសាសម្ភាសន៍ជ្រើសរើសមន្ត្រីលក្ខន្តិកៈ ចំនួន១៥រូប ឱ្យចូលបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលប្រព្រឹត្តទៅនៅបន្ទប់ប្រជុំនិយ័តករគណនេយ្យនិងសវនកម្ម ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនជាមន្ត្រីលក្ខន្តិកៈ។

## សិក្ខាសាលាជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានទាំង១០ប្រទេស ស្តីពី “ASEAN-4IR Professionals' Development” នៅខេត្តសៀមរាប



៦.កាលពីថ្ងៃទី៤-១០ ខែមិថុនា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ណុប សម្បត្តិ** អនុប្រធាននាយកដ្ឋានបានដឹកនាំមន្ត្រី ជំនាញរួមមាន **លោក ជ រ័ត្ននា** អនុប្រធានការិយាល័យ និង **លោក យេង សុខធី** មន្ត្រីនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមសិក្ខាសាលាជាមួយបណ្តា ប្រទេសជាសមាជិកអាស៊ានទាំង១០ប្រទេសស្តីពី “ASEAN-4IR Professionals' Development” នៅខេត្តសៀមរាប។ សិក្ខាសាលានេះផ្តោតសំខាន់ទៅលើ “បដិវត្តន៍ឧស្សាហកម្ម ៤.០” នៅក្នុងការធ្វើសកម្មភាពធុរកិច្ចនិងហិរញ្ញវត្ថុ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងការពង្រីកទីផ្សារនិងផលិតភាពគួបផ្សំនឹងប្រសិទ្ធភាពសេដ្ឋកិច្ចនឹងជួយឱ្យមានការបង្កើតនូវធុរកិច្ចថ្មីក៏ត្រូវបានហៅថា “ធុរកិច្ចឌីជីថលដែលរួមទាំងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងបច្ចេកវិទ្យាហិរញ្ញវត្ថុ”។ ការធ្វើឌីជីថលភាវូបនីយកម្មលើច្រវាក់ផលិតកម្ម,លើផលិតផលនិងសេវានិងគំរូធុរកិច្ច ជាដើមនៅក្នុងវិស័យឧស្សាហកម្ម។ ប្រធានបទសំខាន់ៗនៃសិក្ខាសាលាដែលបានបង្ហាញរួមមាន៖ Internet-of-Things (IOT), Industrial-Internet-of-Things (IIOT), Internet-of-Services (IOS) និង Internet-of-Everything (IOE) ឧស្សាហកម្ម ៤.0 (4IR) សុវត្ថិភាព ភាពរសើប នៃទិន្នន័យ និងគម្លាតក្នុងជំនាញបច្ចេកទេសត្រូវបានពិភាក្សាដើម្បីបញ្ជាក់ពីបញ្ហាប្រឈមរបស់ 4IR ជាមួយនឹងបច្ចេកវិទ្យា បញ្ញាសិប្បនិម្មិត (AI) ដែលកំពុងរីកចម្រើនរួមទាំងបញ្ហាប្រឈម, ភាពចាំបាច់នៃឧបករណ៍ និងចំណេះដឹងផ្នែកបញ្ញាសិប្បនិម្មិត (AI) ការគ្រប់គ្រងការប្រើប្រាស់ បញ្ញាសិប្បនិម្មិត (AI) ប្រកបដោយការទទួលខុសត្រូវ។

## កិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុលើកទី៥




៧.កាលពីថ្ងៃចន្ទ ១១ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុលើកទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងជាប្រធានក្រុមការងារមណ្ឌលហិរញ្ញវត្ថុ។ ដើម្បីពិភាក្សាទៅលើកិច្ចការមួយចំនួន០២គឺ៖ ធាតុចូលរបស់និយ័តករ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ លើផែនការសកម្មភាពសម្រាប់រយៈពេល១០ឆ្នាំ (២០២៤-២០៣៣) របស់ក្រុមហ៊ុន CSD និងសេចក្តីព្រាងអនុក្រឹត្យស្តីពី “ការរៀបចំនឹងការប្រព្រឹត្តទៅរបស់គណៈកម្មការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ” និង សេចក្តីព្រាងអនុក្រឹត្យស្តីពី “ការកំណត់ទីតាំងនៃមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ”។

# ទស្សនកិច្ចសិក្សាទៅកាន់វិទ្យាស្ថានហិរញ្ញវត្ថុសាធារណៈកូរ៉េ (KIPF) ក្រុមប្រឹក្សាស្តង់ដា គណនេយ្យកូរ៉េ (KASB) និងក្រុមប្រឹក្សាស្តង់ដាចីរភាពកូរ៉េ (KSSB)




៨.កាលពីថ្ងៃព្រហស្បតិ៍ ៨កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ នៅប្រទេសកូរ៉េខាងត្បូង ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី នាន បូនី** អគ្គនាយករង អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានធ្វើទស្សនកិច្ចសិក្សាទៅកាន់វិទ្យាស្ថានហិរញ្ញវត្ថុសាធារណៈកូរ៉េ (KIPF) ក្រុមប្រឹក្សាស្តង់ដាគណនេយ្យកូរ៉េ (KASB) និងក្រុមប្រឹក្សាស្តង់ដាចីរភាពកូរ៉េ (KSSB) ដើម្បីជួបពិភាក្សាទៅលើ៖១)ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េស្របទៅតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិមូលដ្ឋានបង្គរ។ ២)ការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ IFRS ជាពិសេសការដាក់ឱ្យអនុវត្តស្តង់ដា IFRS 17 នៅប្រទេសកូរ៉េខាងត្បូង និងបញ្ហាប្រឈម និង៣)ការត្រៀមដាក់ឱ្យអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានអំពីចីរភាពនៅប្រទេសកូរ៉េខាងត្បូង (Korean Sustainability Disclosure Standards)។

# សិក្ខាសាលាផ្សព្វផ្សាយ “ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ” សម្រាប់ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ខេត្តបាត់ដំបង



៩.កាលពីថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានសហការជាមួយ សាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ចខេត្តបាត់ដំបង រៀបចំសិក្ខាសាលាផ្សព្វផ្សាយ “ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និង បទប្បញ្ញត្តិពាក់ព័ន្ធ” សម្រាប់សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ចខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព។ សិក្ខាសាលា នេះមានការអញ្ជើញចូលរួមពី **លោក យុទ្ធ ចេតនា** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ចតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ទុន ភក្តី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ខេត្តបាត់ដំបង ព្រមទាំង សាស្ត្រាចារ្យ និងនិស្សិត ថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម សរុបចំនួន១៨០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីច្បាប់  និងបទប្បញ្ញត្តិ ពាក់ព័ន្ធ នឹងគណនេយ្យនិងសវនកម្ម ព្រមទាំងស្តង់ដាបច្ចេកទេសនៅកម្ពុជាដល់ សាស្ត្រាចារ្យ និងនិស្សិតដែលកំពុងសិក្សាជំនាញពាក់ព័ន្ធ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី “កាតព្វកិច្ចគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ” សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ នៅសណ្ឋាគារស្ទឹងសង្កែខេត្តបាត់ដំបង



១០.កាលពីថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី “កាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ” សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ នៅសណ្ឋាគារស្ទឹងសង្កែ ខេត្តបាត់ដំបង។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព។ សិក្ខាសាលា នេះក៏មានការអញ្ជើញចូលរួមពី **ឯកឧត្តម អ៊ុយ សុធារី** អភិបាលរងខេត្តបាត់ដំបង និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម សុខ លូ** អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និង **លោក យាន បារាំង** តំណាង **អ្នកឧកញ៉ា ភួ វាសនា** ប្រធានសភាពាណិជ្ជកម្មមណ្ឌល បាត់ដំបង និងមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម សមាជិកសមាជិកាសភាពាណិជ្ជកម្មមណ្ឌលបាត់ដំបង ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ សរុបចំនួន១៧០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីកាតព្វកិច្ចគណនេយ្យនិងសវនកម្ម  និងបទប្បញ្ញត្តិ

ពាក់ព័ន្ធ ជូនដល់បុគ្គលជាប់កាតព្វកិច្ច និងអ្នកដែលមានការទទួលខុសត្រូវលើកិច្ចការគណនេយ្យរបស់សហគ្រាសនិងអង្គភាព មិនស្វែងរកប្រាក់ចំណេញ។

## កិច្ចប្រជុំលើកទី៤៩ របស់គណៈកម្មាធិការសវនកម្មអាស៊ាន (AAC)




១១.កាលពីថ្ងៃសុក្រ១៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ នៅលេខាធិការដ្ឋានអាស៊ានប្រទេសឥណ្ឌូនេស៊ី ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ជេន ជាត** អគ្គនាយករង អមដោយ**លោក ឈុត វិឆ័យ** អនុប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិកនៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមកិច្ចប្រជុំលើកទី៤៩របស់គណៈកម្មាធិការសវនកម្ម អាស៊ាន (AAC) ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៣ របស់លេខាធិការដ្ឋានអាស៊ាន (ASEC), ការពិនិត្យតាមដានវឌ្ឍនភាពលើការអនុវត្តអនុសាសន៍របស់សវនករផ្ទៃក្រៅ (សវនករឯករាជ្យ) ឆ្នាំ២០២២ និងអនុសាសន៍ឆ្នាំ២០២៣, ការពិនិត្យនិងអង្កេតលើរបាយការណ៍ស្តីពីការគ្រប់គ្រងហានិភ័យ របស់លេខាធិការដ្ឋានអាស៊ាន និងការពិចារណាលើរបាយការណ៍ និងលទ្ធផលនៃផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០២៣/២០២៤ ព្រមទាំងផែនការសវនកម្មប្រចាំឆ្នាំ ២០២៤/២០២៥ និងការបណ្តុះបណ្តាលនៃផ្នែកសវនកម្ម និងវាយតម្លៃផ្ទៃក្នុង (IAED)។

## មហាសន្និបាត វ.គ.ស.ក. ប្រចាំឆ្នាំលើកទី២១ នៅសណ្ឋាគារសុខាភ្នំពេញ



១២.កាលពីថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមជាអធិបតីភាពនៅក្នុងមហាសន្និបាត វ.គ.ស.ក. ប្រចាំឆ្នាំលើកទី២១ ដែលរៀបចំដោយ វ.គ.ស.ក. នៅសណ្ឋាគារសុខាភ្នំពេញ។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមអគ្គនាយក** ក៏បានមានមតិថ្លែងអំណរគុណ

យ៉ាងជ្រាលជ្រៅចំពោះការខិតខំប្រឹងប្រែងរបស់ ប្រធាន អនុប្រធាន និងសមាជិក សមាជិកា ក្រុមប្រឹក្សាភិបាល វ.គ.ស.ក. អាណត្តិទី៦ ដែលបានយកអស់កម្លាំងកាយចិត្ត បញ្ញាស្មារតី ចំណេះជំនាញក្នុងការដឹកនាំស្ថាប័ន វ.គ.ស.ក. និងចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍វិជ្ជាជីវៈ និងវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។ ជាមួយគ្នានេះដែរ **ឯកឧត្តមអគ្គនាយក** ក៏បានប្រកាស និងស្នើដល់អស់លោក លោកស្រី ប្រធាន និងសមាជិក វ.គ.ស.ក. ព្រមទាំងសាធារណៈជនទាំងអស់ អញ្ជើញចូលរួមកម្មវិធីវេទិកាគណនេយ្យជាតិឆ្នាំ២០២៤ ក្រោមប្រធានបទ “តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២៤ ខាងមុខនេះ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។

## វគ្គបណ្តុះបណ្តាលស្តីពី “ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាស ធុនតូចនិងមធ្យម”



១៣.កាលពីថ្ងៃសៅរ៍១រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី “ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម” រយៈពេល៦ថ្ងៃ នៅអគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី **លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុនឌីអេស្វស៊ី (DFC) ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃនិយ័តករ គណនេយ្យនិងសវនកម្ម ក្នុងនោះសម្រាប់វគ្គនេះក៏មានការចុះឈ្មោះចូលរួមពីសំណាក់ក្រុមហ៊ុន សហគ្រាស និងបុគ្គលជាប់កាតព្វកិច្ច ទទួលខុសត្រូវលើកិច្ចការគណនេយ្យសរុបចំនួន៥១នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅបញ្ជ្រាបការ យល់ដឹងនិងសិក្សាលម្អិតលើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាមូលដ្ឋាន ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់ការចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យ និង សវនកម្មដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## សិក្ខាសាលាផ្សព្វផ្សាយ “ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ” ជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា



១៤.កាលពីថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹង ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានសហការជាមួយសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដារៀបចំសិក្ខាសាលាផ្សព្វផ្សាយ"ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ"ជូនដល់ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិតនៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព។ សិក្ខាសាលានេះក៏មានការអញ្ជើញចូលរួមពី **លោកបណ្ឌិត ផុន ណារិន** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា ព្រមទាំង **លោកស្រី សាវុធ ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករ ជំនាញនិងសវនករកម្ពុជា ព្រមទាំង លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងថ្នាក់ដឹកនាំ មន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម សរុបចំនួន២០០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងបញ្ជ្រាបការការយល់ដឹងអំពី ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងស្តង់ដាបច្ចេកទេសនៅកម្ពុជា និងវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា ជូនដល់ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ដែលកំពុងសិក្សាជំនាញពាក់ព័ន្ធ។

## ការបង្ហាញខ្លួនរបស់បេក្ខជនបេក្ខនារី ដែល ជាមន្ត្រីលក្ខនិក្កៈទាំង ១៥រូប នៃ ន.គ.ស.



១៥.កាលពីថ្ងៃអង្គារ ៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ) បានរៀបចំឱ្យមានការបង្ហាញខ្លួនរបស់បេក្ខជន បេក្ខនារី ដែលបានប្រឡងជាប់ស្ថាពរជាមន្ត្រីលក្ខនិក្កៈទាំង១៥រូប មកបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម និងវគ្គបណ្តុះបណ្តាលតម្រង់ទិស ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពីតួនាទីភារកិច្ច បទបញ្ជាផ្ទៃក្នុង និងបទដ្ឋានគតិយុត្តអំពីនាយកដ្ឋានទាំងអស់ដែលនៅស្ថិតក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះដែរត្រូវបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ លោកអគ្គនាយករង និងលោក លោកស្រី ដែលជាអនុប្រធាននាយកដ្ឋាន និងមន្ត្រី នៃ ន.គ.ស. ផងដែរ ។

# សិក្ខាសាលាស្តីពី “ការជំរុញការប្រើប្រាស់និងការអភិវឌ្ឍន៍ថ្នាលឌីជីថល គ្រឹះក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ”



១៦.កាលពីព្រឹកថ្ងៃអង្គារ ៤ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ មិថុនា ឆ្នាំ២០២៤ នៅទីស្តីការនៃ អ.ស.ហ. **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋាន និង**លោក ជីវ ហ៊** ប្រធានការិយាល័យ ព្រមទាំងមន្ត្រីជំនាញចំនួន ៣រូប បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី“ការជំរុញការប្រើប្រាស់និងការអភិវឌ្ឍន៍ថ្នាលឌីជីថលគ្រឹះក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ”ក្រោមអធិបតីភាពរបស់ **ឯកឧត្តម គុយ សារុធ អគ្គលេខាធិការរង** នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.។ គោលបំណងនៃសិក្ខាសាលានេះគឺដើម្បីបញ្ជ្រាបការយល់ដឹងក្នុងការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលមានស្រាប់និងជំរុញការអភិវឌ្ឍន៍ថ្នាលឌីជីថលគ្រឹះផ្សេងទៀត និងចូលរួមអនុវត្តវិធានការគោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ សំដៅជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

# កិច្ចប្រជុំនេះបានពិភាក្សាអំពីការពន្យារពេលការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាលេខ ១៧“កិច្ចសន្យាធានារ៉ាប់រង” របស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភិអិលសុី



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១៧.កាលពីព្រឹកថ្ងៃសុក្រ ៧រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ នៅសាលប្រជុំធំ ន.គ.ស. **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ**លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុកបម្រើ នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចពិភាក្សាជាមួយតំណាងធនាគារជាតិនៃកម្ពុជា,តំណាងសមាគមធនាគារនៅកម្ពុជា,តំណាងធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភិអិលស៊ី (BIDC PLC), និងតំណាងក្រុមហ៊ុន អឺនស្ថ៍ អ៊ែន យ៉ាំង (ខេមបូឌា)។ កិច្ចប្រជុំនេះបានពិភាក្សាអំពីការពន្យារពេលការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាលេខ ១៧“កិច្ចសន្យាធានារ៉ាប់រង”របស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភិអិលស៊ី។

## កិច្ចប្រជុំពិភាក្សាជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជាស្ថាប័ន ACCA និងសហព័ន្ធគណនេយ្យករអន្តរជាតិ




១៨.កាលពីព្រឹកថ្ងៃសុក្រ ៧ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ណុប សម្បត្តិ** អនុប្រធាននាយកដ្ឋាន អមដោយ**លោក សេង ម៉េងហ័រ** មន្ត្រីជំនាញ នៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា, ស្ថាប័ន ACCA និងសហព័ន្ធគណនេយ្យករអន្តរជាតិ ស្តីពីលក្ខខណ្ឌតម្រូវដើម្បីក្លាយជាសមាជិកពេញសិទ្ធរបស់សហព័ន្ធគណនេយ្យករអន្តរជាតិតាមប្រព័ន្ធអនឡាញ(Microsoft Teams)។

រៀបចំដោយ÷**លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ÷**កញ្ញា សុខ ណាវី**

©រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម